សកម្មភាព ៖ **ល្បែងថ្ងៃចូលរៀនដំបូង**

**សិក្សាសង្គម**

ការយល់ដឹងអំពីខ្លួនឯង(ស្គាល់ពីអារម្មណ៍មួយចំនួន)

(សម្តែងអារម្មណ៍ និងចេះសង្កត់ចិត្តរបស់ខ្លួន)

គំនូរ និងសកម្មភាពកសាង(ការយល់ដឹងពីភាពបឆ្លាស់នៃ វត្ថុតាមចង្វាក់ និងការគូរគំនូរ)។

**គោលបំណង** ៖

**(សិក្សាសង្គម)** ប្រាប់បានពីអារម្មណ៍ និងមូលហេតុដែលធ្វើឱ្យខ្លួនសប្បាយ ត្រេកអរ ភ័យ ខ្លាចនៅពេលជួបព្រឹត្តិការណ៍ណាមួយ។

បង្ហាញកាយវិការ ឬនិយាយបានអំពីសេចក្តីស្រលាញ់ និងទំនាក់ទំនងជាមួយមនុស្សដែលនៅជុំវិញខ្លួន។

ទំនាក់ទំនងល្អទាំងកាយវិការ និងសម្តីប្រកបដោយសេចក្តីស្រលាញ់ជាមួយមនុស្សដែលនៅជុំវិញ។

ប្រាប់បានពីអារម្មណ៍ និងគ្រប់គ្រងអារម្មណ៍នៅពេលជួបរឿងមិនសប្បាយចិត្តនិងសប្បាយចិត្តដោយធ្វើកាយវិការ។

សម្តែងអារម្មណ៍ផ្ទាល់ខ្លួនដោយ ខឹង ស្រលាញ់ ស្អប់ តាមរយៈកាយវិការ និងពាក្យសម្តីសម្របខ្លួន និងទប់អារម្មណ៍មិនឱ្យឆាប់ខឹងនឹងស្ថានភាពមនុស្សជុំវិញ។

ទទួលស្គាល់បរាជ័យរបស់ខ្លួន និងភាព ជោគជ័យរបស់ដៃគូលេងជាមួយកែប្រែទម្លាប់អវិជ្ជមានដើម្បីរស់នៅក្នុងសង្គម។

ប្រាប់ពីរបៀបដោតអង្កាំ គូសគំនូស និងគំនូរ។

គូររូបមនុស្សយ៉ាងតិច ៦ផ្នែកខុសៗគ្នារួមមានក្បាលដងខ្លួន ដៃ ជើងប្រអប់ដៃ ប្រអប់ជើង។ សប្បាយរីករាយនិងទទួលស្គាល់សមិទ្ធផល ការងាររបស់ខ្លួន។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "កុមារគំរូ"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាស និងខ្មៅដៃពណ៌

**ការរៀបចំ** ៖ ត្រៀបខ្លួនក្នុងការសួរ និងនិយាយជាមួយក្មេងៗ

**សេក្តីណែនាំ៖**

1. សួរក្មេងៗថា តើកូនៗនៅចាំថ្ងៃចូលរៀនដំបូងនៅសាលាដែរឬទេ?
   - បាទ/ចាស ចាំ/មិនចាំទេ។
2. សួរក្មេងៗថា តើកូនៗមានអារម្មណ៍បែបណាក្នុងថ្ងៃចូលរៀនដំបូង?
   - ដូចជា៖ សប្បាយ នឹកប៉ាម៉ាក់ ភ័យខ្លាច សោកសៅ រំភើប ចង់មកសាលា មិនចង់មកសាលាទេ។
3. សួរបណ្តើរ គូររូបទឹកមុខដែលក្មេងៗបានឆ្លើយបណ្តើរនៅក្តារខៀន ។
4. ប្រាប់ក្មេងៗថា ‹អារម្មណ៍អ្នកក្នុងថ្ងៃចូលរៀនដំបូងក៏បែបហ្នឹងដែរ›
5. ពិភាក្សាថា កូនៗគ្រប់គ្នាមានអារម្មណ៍ផ្សេងៗគ្នានៅក្នុងថ្ងៃចូលរៀនដំបូង ដូចជា៖ សប្បាយរីករាយ ក្រៀមក្រំ រំភើប ភ័យខ្លាច …។ ចុះហេតុអ្វីបានជាយើងមានអារម្មណ៍បែបហ្នឹង?
6. កូនៗត្រូវដឹងថាជារឿងធម្មតាសម្រាប់មនុស្សយើងដែលមានអារម្មណ៍ផ្សេងៗគ្នា ព្រោះមនុស្សយើងមានរូបរាងកាយ កាគិតខុសពីគ្នា។
7. ចែកក្រដាស និងខ្មៅដៃពណ៌ឱ្យទៅក្មេងៗ ម្នាក់១សន្លឹក។
8. ប្រាប់ក្មេងៗថា ឥឡូវកូនៗគូរទឹកមុខដែលពួកគេមានក្នុងថ្ងៃចូលរៀនដំបូងនៅសាលារៀងៗខ្លួន ឬ គូររូបភាពដែលកូនៗចងចាំនៅក្នុងថ្ងៃចូលរៀនដំបូងក៏បានដែរ។